*រៀបរៀងដោយ វេជ្ជ.ហេង ណៃឃីម / វេជ្ជ.ពឹង យ៉ឹកស៊ីង / ខែមេសា ឆ្នាំ២០១៥*

# វ៉ាក់សាំងបង្ការជំងឺរលាកថ្លើម ប្រភេទអា (Hepatitis A Vaccine)

## ១- តើជំងឺរលាកថ្លើមប្រភេទអាជាអ្វី?

ជំងឺរលាកថ្លើម ប្រភេទអា គឺជាជំងឺថ្លើមធ្ងន់ធ្ងរមួយ ដែលបណ្តាលមកពីមេរោគរលាកថ្លើមប្រភេទអា។

មេរោគរលាកថ្លើមប្រភេទអាត្រូវបានរកឃើញក្នុងលាមកនៃអ្នកជំងឺ។ មេរោគនេះឆ្លងតាមការប៉ះពាល់ផ្ទាល់យ៉ាងជិតស្និទ្ធជាមួយអ្នកជំងឺ និងការបរិភោគចំណីអាហារ រឺទឹកមិនស្អាតដែលមានផ្ទុកមេរោគ។

រោគសញ្ញានៃអ្នកជំងឺរលាកថ្លើមប្រភេទអារួមមាន៖

- ប្រជុំរោគសញ្ញាស្រដៀងនឹងជំងឺផ្តាសាយ
- ខាន់លឿង ឈឺពោះខ្លាំង និងរាគរូស ជាញឹកញាប់ ការបង្ករោគដោយមេរោគរលាកថ្លើម ប្រភេទអា នេះ តំរូវអោយ សំរាកពេទ្យដើម្បីព្យាបាល (ប្រហែល ២០%)។ ចំពោះមនុស្សពេញវ័យ វាអាចមានអាការៈធ្ងន់ធ្ងរដែលមិនអាចធ្វើការបានរយៈពេលយូរ (ប្រហែល ១ខែ)។

អត្រាស្លាប់ដោយសារជំងឺរលាកថ្លើម ប្រភេទអា មានប្រមាណពី ៣ ទៅ ៦ ករណី ក្នុងចំណោមអ្នកជំងឺ ១០០០ នាក់។

## ២- តើអ្នកណាខ្លះគួរទទួលវ៉ាក់សាំងបង្ការជំងឺនេះ? ហើយគួរធ្វើនៅពេលណា?

វ៉ាក់សាំងបង្ការនេះត្រូវបានណែនាំអោយប្រើសំរាប់៖

១- កុមារទាំងអស់ដែលមានអាយុចាប់ពី១២-២៣ ខែ

២- កុមារនិងមនុស្សធំដែលមានអាយុពី ២-១៨ឆ្នាំ ដែលរស់នៅតំបន់ដែលប្រឈមនឹងជំងឺនេះ

៣- អ្នកធ្វើដំណើរទៅតំបន់ដែលប្រឈមនឹងការឆ្លងជំងឺនេះខ្ពស់ ដូចជាតំបន់អាស៊ី តំបន់អាហ្វ្រិច តំបន់អាមេរិចកណ្តាល អាមេរិចខាងត្បូងជាដើម

៤- បុរសដែលរួមភេទដូចគ្នា

៥- អ្នកប្រើប្រាស់គ្រឿងញៀន

៦- អ្នកមានជំងឺថ្លើមរ៉ាំរ៉ៃ

៧- អ្នកព្យាបាលដោយថ្នាំប្រឆាំងនឹងឈាមកក

៨- អ្នកដែលធ្វើការជាមួយសត្វដែលមានផ្ទុកមេរោគ រឺអ្នកមន្ទីរពិសោធន៍ដែលប្រឈមនឹងមេរោគនេះ

៩- អ្នករស់នៅក្នុងសហគមន៍ដែលជំងឺនេះផ្ទុះឡើង

១០- អ្នកដែលមានបំណងការពារការបង្ករោគដោយមេរោគរលាកថ្លើមប្រភេទអានេះ

*** វ៉ាក់សាំងបង្ការរលាកថ្លើមប្រភេទអានេះពុំត្រូវបានអនុញ្ញាតឲ្យចាក់លើកុមារអាយុតិចជាង ១ឆ្នាំ ឡើយ។**

ដើម្បីអោយមានប្រសិទ្ធភាពយូរអង្វែង វ៉ាក់សាំងនេះត្រូវបានគេណែនាំអោយចាក់ចំនួន ២ ដូស៖

- ដូសទី១: នៅអាយុ ១២-២៣ខែ រឺពេលប្រឈមនឹងការឆ្លង
- ដូសទី២: ៦ខែ បន្ទាប់ពីដូសទី១។ ដើម្បីអោយមានប្រសិទ្ធភាពខ្ពស់ វ៉ាក់សាំងគួរតែត្រូវបានផ្តល់អោយយ៉ាងហោចណាស់ នៅពេល ១ខែមុនពេលធ្វើដំណើរទៅតំបន់ដែលប្រឈមនឹងជំងឺនេះ។

## ៣- តើអ្នកណាខ្លះដែលមិនគួរទទួលវ៉ាក់សាំងនេះ?

- អ្នកដែលធ្លាប់មានប្រវត្តិប្រតិកម្មធ្ងន់ធ្ងរជាមួយនឹងវ៉ាក់សាំងប្រភេទនេះពីមុន ឬធ្លាប់ប្រតិកម្មធ្ងន់ធ្ងរជាមួយសមាសធាតុផ្សំផ្សេងទៀតដែលមាន ក្នុងវ៉ាក់សាំងនេះ
- អ្នកដែលមានជំងឺកំរិតមធ្យម រឺធ្ងន់ធ្ងរ (ការផ្តល់វ៉ាក់សាំងនេះគួរត្រូវបានពន្យាររហូតដល់ពេលជាសះស្បើយពីជំងឺជាមុនសិន)។

## ៤- ផលវិបាកដែលអាចកើតមានក្រោយចាក់វ៉ាក់សាំង

ដូចឱសថផ្សេងៗទៀតដែរ វ៉ាក់សាំងអាចបណ្តាលអោយមានផលវិបាកធ្ងន់ធ្ងរ ដូចជាប្រតិកម្មអាលែកស៊ីជាដើម។ ប៉ុន្តែលទ្ធភាពដែលវ៉ាក់សាំងនេះអាចបណ្តាលអោយមានផលវិបាកធ្ងន់ធ្ងរមានតិចតួចបំផុត។ ផលវិបាកដែលអាចកើតឡើងរួមមាន៖

- ឈឺ ឬ ហើមត្រង់កន្លែងចាក់
- គ្រុនក្តៅ ឈឺក្បាល
- ឡើងកន្ទួលក្រហមលើស្បែក
- ប្រតិកម្មធ្ងន់ធ្ងរ (កំរមានណាស់)

**ប្រសិនបើមានសញ្ញាប្រតិកម្មធ្ងន់ធ្ងរ សូមជូនដំណឹងដល់គ្រូពេទ្យជាបន្ទាន់!**